ADVANCE CARE DIRECTIVE.

KHMER

Government of South Australia

Advance Care Directive (សេចក្តីបង្គាប់លើការមើលថែក្នុងដំណាក់កាលចុងក្រោយនៃជីវិត)

# សេចក្តីប្រកាសព័ត៌មាន

សាក្សីរបស់លោកអ្នក នឹងស្នើសុំឲ្យលោកអ្នកអានសេចក្តីប្រកាសព័ត៌មាននេះ បន្ទាប់មកនឹងសួរសំណួរលោកអ្នកមួយចំនួនដើម្បីឲ្យច្បាស់ប្រាកដថា លោកអ្នកយល់ដឹងអំពីអ្វីដែលលោកអ្នកកំពុងធ្វើដោយធ្វើ Advance Care Directive (សេចក្តីបង្គាប់លើការមើលថែក្នុងដំណាក់កាលចុងក្រោយនៃជីវិត)។

## តើ Advance Care Directive ជាអ្វី?

Advance Care Directive គឺជាបែបបទស្របច្បាប់មួយដែលអនុញ្ញាតឲ្យមនុស្សអាយុចាប់ពី១៨ឆ្នាំឡើងទៅ:

- សរសេរចុះអំពីការប៉ងប្រាថ្នា ចំណូលចិត្តជាងគេ និងសេចក្តីណែនាំរបស់គេ សម្រាប់ការមើលថែសុខភាពនៅពេលអនាគត ការបញ្ចប់ជីវិតរស់នៅ ការរៀបចំរបៀបរស់នៅ និងបញ្ហាផ្ទាល់ខ្លួនរបស់គេ និង/ឬ
- តែងតាំងអ្នកធ្វើការសម្រេចចិត្តជំនួសម្នាក់ ឬច្រើននាក់ ដើម្បីធ្វើការសម្រេចចិត្តទាំងអស់នេះជំនួសគេ ពេលណាគេពុំអាចធ្វើដូច្នោះបានដោយខ្លួនគេ។

ពុំអាចគេយកបែបបទនេះសម្រាប់ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុឡើយ។

ប្រសិនបើលោកអ្នកបានសរសេរចុះ អំពីការបដិសេធលើការមើលថែសុខភាព គេត្រូវបំពេញតាមសេចក្តីប៉ងប្រាថ្នារបស់លោកអ្នក ប្រសិនបើវាពាក់ព័ន្ធនឹងកាលៈទេសៈនៅពេលនោះ។ ព័ត៌មានដទៃទៀតទាំងអស់ដែលសរសេរចុះក្នុង Advance Care Directive របស់លោកអ្នក គឺជាការផ្តល់យោបល់ ហើយគួរបានយកប្រើ ជាសេចក្តីណែនាំសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តដោយអ្នកធ្វើការសម្រេចចិត្តជំនួសរបស់លោកអ្នក គ្រូពេទ្យព្យាបាលសុខភាពរបស់លោកអ្នក ឬនរណាម្នាក់ទៀត ដែលធ្វើសេចក្តីសម្រេចចិត្តក្នុងនាមលោកអ្នក។

នេះគឺការជ្រើសរើសរបស់លោកអ្នកទេ ថាតើត្រូវឲ្យមាន Advance Care Directive ឬអត់។ ពុំមាននរណាម្នាក់អាចបង្ខំលោកអ្នកឲ្យធ្វើសេចក្តីបង្គាប់ណាមួយ ឬឲ្យលោកអ្នកសរសេរចុះនូវកិច្ចការទាំងឡាយណាដែលលោកអ្នកពុំចង់ធ្វើនោះឡើយ។ ការទាំងនេះ គឺជាបទល្មើសក្រោមផ្លូវច្បាប់។

លោកអ្នកអាចផ្លាស់ប្តូ Advance Care Directive របស់លោកអ្នកនៅពេលណាក៏បាន ខណៈដែលលោកអ្នកនៅអាចធ្វើបាន ដោយបំពេញបែបបទ Advance Care Directive ថ្មីមួយ។

បែបបទ Advance Care Directive ថ្មីរបស់លោកអ្នក នឹងជំនួសឯកសារដទៃទៀតទាំងអស់ ដែលលោកអ្នកប្រហែលជាបានបំពេញពីលើកមុន ឧទាហរណ៍ Enduring Power of Guardianship (បែបបទអាណាព្យាបាលបិតបេរ), Medical Power of Attorney (បែបបទអ្នកធ្វើសេចក្តីសម្រេចចិត្តជំនួសផ្នែកពេទ្យ) ឬ Anticipatory Direction (បែបបទការព្យាបាលដែលសាមីខ្លួនចង់បាន ឬពុំចង់បាន)។

## តើគេនឹងប្រើបែបបទនេះនៅពេលណា?

Advance Care Directive របស់លោកអ្នកនឹងត្រូវចាប់ផ្តើមប្រតិបត្តិប៉ុណ្ណោះ(អាចត្រូវគេប្រើប៉ុណ្ណោះ) ប្រសិនបើលោកអ្នកពុំមានសមត្ថភាពនឹងធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង ទោះបីជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ក្តី។

ប្រសិនបើលោកអ្នកពុំអាចៈ

- យល់ដឹងព័ត៌មានអំពីសេចក្តីសម្រេចចិត្ត
- យល់ដឹង និងទទួលស្គាល់អំពីការប្រឈមនឹងគ្រោះថ្នាក់ និងគុណប្រយោជន៍នៃការជ្រើសរើស
- ចងចាំព័ត៌មានក្នុងរយៈពេលខ្លី ហើយ
- និយាយប្រាប់នរណាម្នាក់អំពីសេចក្តីសម្រេចចិត្ត ហើយថាហេតុអ្វីបានជាលោកអ្នកធ្វើការសម្រេចចិត្ត។

ការនេះមានន័យថា លោកអ្នកពុំអាចធ្វើសេចក្តីសម្រេចចិត្តបានឡើយ (ជួនកាលហៅថា សមត្ថភាពធ្វើការសម្រេចចិត្តអន់ថយ) ហើយនរណាម្នាក់ទៀតនឹងត្រូវការធ្វើសេចក្តីសម្រេចចិត្តសម្រាប់លោកអ្នក។

Advance Care Directive (សេចក្ដីបង្គាប់លើការមើលថែក្នុងដំណាក់កាលចុងក្រោយនៃជីវិត)

# សេចក្តីប្រកាសព័ត៌មាន

## តើនរណានឹងធ្វើសេចក្ដីសម្រេចចិត្តសម្រាប់លោកអ្នក នៅពេលលោកអ្នកពុំអាចធ្វើបាន?

នេះជាជម្រើសរបស់លោកអ្នកទេ ដែលថាលោកអ្នកចង់តែងតាំងអ្នកធ្វើការសម្រេចចិត្តជំនួសម្នាក់ ឬច្រើននាក់។ ប្រសិនបើលោកអ្នកបានតែងតាំងអ្នកធ្វើការសម្រេចចិត្តជំនួសម្នាក់ ឬច្រើននាក់ គេនឹងអាចធ្វើសេចក្ដីសម្រេចស្របច្បាប់សម្រាប់លោកអ្នក អំពីការមើលថែសុខភាព ការរៀបចំរបៀបរស់នៅ និងបញ្ហាផ្ទាល់ខ្លួនដទៃទៀតរបស់លោកអ្នក នៅពេលលោកអ្នកពុំអាចធ្វើបាន។ លោកអ្នកអាចបញ្ជាក់ច្បាស់លាស់អំពីប្រភេទនៃសេចក្ដីសម្រេចចិត្តដែលលោកអ្នកចង់ឲ្យគេធ្វើ ក្នុងល័ក្ខខ័ណ្ឌនៃការតែងតាំង ផ្នែក 2b នៃ Advance Care Directive។

ប្រសិនបើលោកអ្នកពុំតែងតាំងអ្នកធ្វើការសម្រេចចិត្តជំនួសណាម្នាក់ទេ អ្នកដទៃទៀតដែលជិតស្និទ្ធនឹងលោកអ្នកអាចត្រូវគេស្នើសុំឲ្យធ្វើសេចក្ដីសម្រេចចិត្តជូនលោកអ្នក ប្រសិនបើលោកអ្នកពុំអាចធ្វើបានទេ(អ្នកទទួលខុសត្រូវ)។ គេត្រូវធ្វើតាមការប៉ងប្រាថ្នា ឬសេចក្ដីណែនាំពាក់ព័ន្ធណាមួយដែលលោកអ្នកបានសរសេរចុះក្នុង Advance Care Directive របស់លោកអ្នក។

នរណាម្នាក់ដែលធ្វើការសម្រេចចិត្តជូនលោកអ្នក នឹងត្រូវការធ្វើសេចក្ដីសម្រេចចិត្តដែលគេគិតថាលោកអ្នកនឹងធ្វើក្នុងកាលៈទេសៈដូចគ្នានេះដែរ។

## ការបដិសេធលើការមើលថែសុខភាព

លោកអ្នកប្រហែលជាបានសរសេរចុះក្នុង Advance Care Directive របស់លោកអ្នកថា លោកអ្នកពុំចង់បានប្រភេទនៃការមើលថែមួយចំនួន ដែលហៅថាការបដិសេធលើការមើលថែសុខភាព។ គឺជាការសំខាន់ដែលត្រូវឲ្យបានច្បាស់ប្រាកដថា លោកអ្នកបានសរសេរចុះ អំពីថាតើការបដិសេធលើការព្យាបាលត្រូវអនុវត្តនៅពេលណា ឬនៅក្រោមកាលៈទេសៈមួយណា។

ប្រសិនបើលោកអ្នកបានបដិសេធលើការមើលថែសុខភាពជាក់លាក់ក្នុង Advance Care Directive របស់លោកអ្នក អ្នកធ្វើការសម្រេចចិត្តជំនួស(អ្នកទទួលខុសត្រូវ) របស់លោកអ្នក និងគ្រូពេទ្យព្យាបាលសុខភាពរបស់លោកអ្នក ត្រូវធ្វើតាមការបដិសេធនោះ ប្រសិនបើវាពាក់ព័ន្ធនឹងកាលៈទេសៈបច្ចុប្បន្ន។

ការនេះមានន័យថា គ្រូពេទ្យព្យាបាលសុខភាពរបស់លោកអ្នកនឹងពុំអាចផ្ដល់ការព្យាបាលមើលថែសុខភាព ដែលលោកអ្នកបានបដិសេធជូនលោកអ្នកបានឡើយ ។

ប្រសិនបើលោកអ្នកបដិសេធលើការមើលថែសុខភាព ក៏ប៉ុន្តែពុំបានសរសេរទុកថាតើពេលណាត្រូវអនុវត្តការបដិសេធនោះ ការនោះនឹងត្រូវអនុវត្តគ្រប់ពេល។

គ្រូពេទ្យព្យាបាលសុខភាពអាចមិនគោរពតាមការបដិសេធនៃការមើលថែសុខភាពប៉ុណ្ណោះ ប្រសិនបើមានភស្តុតាងដែលណែនាំថាលោកអ្នកបានផ្លាស់ប្តូរគំនិតរបស់លោកអ្នក ក៏ប៉ុន្តែពុំបានផ្លាស់ប្ដូរព័ត៌មានទាន់បច្ចុប្បន្នភាពក្នុង Advance Care Directive របស់លោកអ្នក ឬគ្រូពេទ្យព្យាបាលសុខភាពជឿជាក់ថា លោកអ្នកពុំមានបំណងចង់ឲ្យការបដិសេធលើការមើលថែសុខភាព អនុវត្តនៅក្នុងកាលៈទេសៈបច្ចុប្បន្នឡើយ។

ប្រសិនបើការនេះកើតឡើង គេនឹងត្រូវការសេចក្ដីយល់ព្រមពីអ្នកធ្វើការសម្រេចចិត្តជំនួសរបស់លោកអ្នក ប្រសិនបើលោកអ្នកបានជ្រើសរើសនរណាម្នាក់ ឬអ្នកទទួលខុសត្រូវ ដើម្បីផ្ដល់ការមើលថែសុខភាពណាមួយ ។

លោកអ្នកពុំអាចបដិសេធលើការព្យាបាលផ្នែកសុខភាពផ្លូវចិត្តដែលខានពុំបានឡើយ ដូចមានរាយឈ្មោះក្នុងបញ្ជាឲ្យទទួលការព្យាបាលតាមសហគមន៍ ឬដែលពុំស្ម័គ្រចិត្ត ប្រសិនបើលោកអ្នកបានរៀបចំឲ្យមាន។

## ព័ត៌មានបន្ថែម

ប្រសិនបើលោកអ្នកចង់បានព័ត៌មានបន្ថែម សូមអានសេចក្ដីណែនាំចំពោះ Advance Care Directive ដែលបានផ្ដល់មកជាមួយពាក្យបែបបទនេះ ឬតាមអ៊ីនធើណិតនៅត្រង់វិបសាយ www.advancecaredirectives.sa.gov.au